គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ១៨ ចេញផ្សាយថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១
No. 18 Released on November 01, 2021

អត្ថបទប្រចាំសប្ដាហ៍ | Weekly Article

# ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច
# Dispute Resolution in Trust Sector



រូបភាព | Picture: https://docpro.com/news-image/059607f6-aae4-48bc-a921-96e2cd5ec575/1-114-696x336-min%20(1).jpg

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដោះស្រាយដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយបញ្ញត្តិករពាក់ព័ន្ធ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទ ជាកម្មវត្ថុនៃបណ្ដឹងរដ្ឋបាល ឬបណ្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃចេញសេចក្ដីសម្រេច។

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាមសំណើរបស់ **ន.ប.ធ.** (*ច្បាប់ស្ដីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១*)។

Disputes related to the operation of trust in the Kingdom of Cambodia shall be resolved by the Trust Dispute Resolution Council of the Trust Regulator (**TR**), unless otherwise specified by the relevant regulator. The decision of the Dispute Resolution Council is the subject of an administrative complaint or appeal to the competent court within 30 (thirty) days from the date of the decision.

The organization and functioning of the Dispute Resolution Council shall be determined by a Prakas of the Minister of Economy and Finance and Chairman of the Council of the Non-Bank Financial Services Authority at the request of the **TR** (*Law on Trust, 2019; Law on the Organization and Functioning of the Non-Bank Financial Services Authority, 2021; Sub-Decree on the Organization and Functioning of Units Under the Non-Bank Financial Services Authority, 2021*).

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References**:

- មាត្រា៣៤, ច្បាប់ស្ដីពីបរធនបាលកិច្ច. (២០១៩).
- ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).
- អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.